ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៥១៤៣......អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែ មីនា ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធទាំងអស់ដែលធ្លាប់ស្ថិតក្នុងរបបម៉ៅការមុនឆ្នាំ២០១៦ មេត្តាជ្រាបថា ចាប់ពីឆ្នាំ២០១៦ មក រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលប្រកបអាជីវកម្មតូចតាច ដោយមិនយកពន្ធទៅលើប្រជាពលរដ្ឋប្រកបអាជីវកម្ម ដែលមានផលរបរស្ថិតក្រោមកម្រិតត្រូវជាប់ពន្ធ ពោលគឺមានផលរបរប្រចាំឆ្នាំក្រោម ២៥០ លានរៀល។

ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានទទួលព័ត៌មានថា មានជនខិលខូចមួយចំនួនតូច ដែលអាចជាអ្នករត់ការ ឬមន្ត្រីពន្ធដារខិលខូចខ្លះ ប្រើឧបាយកលបោកបញ្ឆោតតាមគ្រប់រូបភាពដល់ប្រជាពលរដ្ឋជាអ្នកជាប់ពន្ធធ្លាប់ស្ថិតក្នុងរបបម៉ៅការ ដែលបច្ចុប្បន្នមានផលរបរស្ថិតក្រោមកម្រិតត្រូវជាប់ពន្ធ ដើម្បីជំរិតទារប្រាក់ ក្រោមរូបភាព ចុះធ្វើសវនកម្ម ឬចុះត្រួតពិនិត្យ ជាដើម។ សូមបងប្អូនប្រជាពលរដ្ឋជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពុំធ្លាប់មានគោលការណ៍ចុះធ្វើសវនកម្ម ឬចុះត្រួតពិនិត្យលើប្រជាពលរដ្ឋប្រកបអាជីវកម្មតូចតាចនោះទេ។

ដូច្នេះ ក្នុងករណីមានបុគ្គលខិលខូចចុះជម្រិតទារប្រាក់ពីអ្នកជាប់ពន្ធប្រកបអាជីវកម្មតូចតាច ដែលមានកម្រិតផលរបរប្រចាំឆ្នាំស្ថិតក្រោមកម្រិតត្រូវជាប់ពន្ធ ក្រោមរូបភាពចុះធ្វើសវនកម្ម ឬចុះត្រួតពិនិត្យ ឬរូបភាពផ្សេងៗទៀត ក្រៅពីការជូនដំណឹងដោយផ្ទាល់ជាលាយលក្ខណ៍អក្សរពីអគ្គនាយកដ្ឋានពន្ធដារដើម្បីអញ្ជើញឱ្យមកធ្វើការចុះបញ្ជីពន្ធដារចំពោះអ្នកជាប់ពន្ធណាដែលមានផលរបរដល់កម្រិតត្រូវជាប់ពន្ធ សូមរាយការណ៍ជាបន្ទាន់មកកាន់អគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋាននៅ អគារលេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងមហាវិថីម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទទំនាក់ទំនងដូចខាងក្រោមនៅរៀងរាល់ម៉ោងធ្វើការ ឬសារអេឡិចត្រូនិក: gdt@tax.gov.kh អគ្គនាយកដ្ឋានពន្ធដារនឹងចាត់វិធានការទៅលើបុគ្គលនោះភ្លាម។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋប្រកបអាជីវកម្មដែលមានផលរបរប្រចាំឆ្នាំដល់កម្រិតត្រូវជាប់ពន្ធ នឹងចូលរួមពង្រឹងវប្បធម៌ក្នុងការបង់ពន្ធដោយអញ្ជើញមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត និងបំពេញកាតព្វកិច្ចសារពើពន្ធផ្សេងៗទៀតតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារឱ្យបានខ្ជាប់ខ្ជួន។

អាស្រ័យហេតុនេះ សូមអ្នកជាប់ពន្ធទាំងអស់ដែលធ្លាប់ស្ថិតក្នុងរបបម៉ៅការ មេត្តាជ្រាប និងចូលរួមសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា
អគ្គនាយកដ្ឋានពន្ធដារ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**លេខទូរស័ព្ទទំនាក់ទំនង៖**
០២៣ ៨៨៦ ៧០៨
០១២ ៩៣២ ០៣២
០១០ ៨៥៨ ៨០២